តើត្រូវចាក់វ៉ាក់សាំងប៉ុន្មានដូស
និងចន្លោះពេលប៉ុន្មាន?






- តាមរយៈព័ត៌មាន គ្រប់វ៉ាក់សាំងទាំងអស់គឺត្រូវចាក់ចំនួនពីរដូស ហើយដូសទីពីរ គឺចាក់ចន្លោះ ៣-១២ សប្តាហ៍ ក្រោយចាក់ដូសទីមួយ។
- ជាការសំខាន់ខ្លាំងណាស់ដែលអ្នកត្រូវទទួលដូសទីពីរ បើមិនដូច្នោះទេ វ៉ាក់សាំងមិនមានប្រសិទ្ធភាពល្អទេ។
- សូមធ្វើតាមការណែនាំរបស់អ្នកផ្តល់ថ្នាំបង្ការ។
- អ្នកត្រូវទទួលដូសទីពីរ ទោះបីមានផលរំខានបន្ទាប់ពីទទួលដូសទីមួយហើយក៏ដោយ លើកលែងតែគ្រូពេទ្យណែនាំមិនឱ្យទទួលដូសទីពីរ។
- អ្នកនឹងទទួលវ៉ាក់សាំងពីក្រុមហ៊ុនតែមួយទាំងពីរដូស។



## ៣ ការពារ



+

## ៣កុំ



+




=

ការពារខ្លួនអ្នក គ្រួសាររបស់អ្នក
និងសហគមន៍ ជាពិសេសជួយ
សង្គ្រោះយើងពីជំងឺកូវីដ-១៩។



# ប្រសិទ្ធភាពរបស់វ៉ាក់សាំងកូវីដ-១៩




unicef
World Health Organization
Representative Office for Cambodia




វ៉ាក់សាំងធ្វើឱ្យប្រព័ន្ធការពាររាងកាយស្គាល់ និងទប់ស្កាត់មេរោគដោយមានប្រសិទ្ធភាព។ វ៉ាក់សាំងមានប្រវត្តិជោគជ័យក្នុងការប្រើប្រាស់អស់រយៈពេល ២២៥ឆ្នាំមកហើយ។ តាមរយៈប្រវត្តិសាស្ត្រ មនុស្សបានបង្កើតវ៉ាក់សាំងដោយជោគជ័យ សម្រាប់ប្រឆាំងនឹងជំងឺដែលអាចបណ្តាលឱ្យពិការភាពអស់មួយជីវិត ឬ ស្លាប់ច្រើន រួមទាំងជំងឺរលាកស្រោមខួរ តេតាណុស កញ្រ្ជឹល គ្រុនស្វិតដៃជើង ហើយឥឡូវនេះគឺជំងឺកូវីដ-១៩។ វ៉ាក់សាំងគឺជាថ្នាំបង្ការថ្មីដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។






## បន្ទាប់ពីខ្ញុំបានចាក់វ៉ាក់សាំងរួច តើប្រព័ន្ធភាពស៊ាំនោះនឹងកើតមានបានរយៈពេលប៉ុន្មាន?

ប្រព័ន្ធភាពស៊ាំនឹងកើតមានក្នុងរយៈពេលប៉ុន្មានខែបន្ទាប់ពីចាក់វ៉ាក់សាំង ប៉ុន្តែបានយូរប៉ុន្មាននោះ គឺនៅមិនទាន់ដឹងនៅឡើយទេ។ ហេតុដូច្នេះហើយ ការអនុវត្តន៍នូវការបង្ការរបស់ក្រសួងសុខាភិបាលដូចជា ពាក់ម៉ាស់ លាងដៃឱ្យបានញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គល និងគម្លាតសុវត្ថិភាពសង្គមនៅតែចាំបាច់ក្នុងរយៈពេលនេះ។ អនុវត្តនូវជំហានទាំងនេះដើម្បីការពារខ្លួនយើង និងមនុស្សជាទីស្រលាញ់ ជាការសំខាន់ណាស់ក្នុងដំណាក់កាលបច្ចុប្បន្ន។







## ប្រសិនបើខ្ញុំធ្លាប់កើត ហើយជាសះស្បើយពីជំងឺកូវីដ-១៩ តើខ្ញុំគួរចាក់វ៉ាក់សាំងកូវីដ-១៩ ដែរ?

ត្រូវហើយអ្នកត្រូវតែទទួល។ វ៉ាក់សាំងកូវីដ-១៩ គួរផ្តល់ឱ្យអ្នកទោះបីជាអ្នកធ្លាប់កើតជំងឺកូវីដ-១៩ ហើយក៏ដោយ។ ការបង្ការដែលបានមកពីវ៉ាក់សាំង គឺផ្តល់ការការពារដែលមានប្រសិទ្ធភាពជាង។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ អ្នកដែលកំពុងតែមានជំងឺកូវីដ-១៩ គួរពន្យាពេលក្នុងការចាក់វ៉ាក់សាំងរហូតដល់បានជាពីជំងឺ និងបានរួចផុតពីគោលការណ៍នៃការធ្វើចត្តាឡីស័ក។

